សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ពាក្យខ្មែរពោលថា ចង់ចេះឲ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កាឲ្យយកភ្លើងដុតគល់ ។

www.hoksavann.org

ថ្ងៃទី១១ កញ្ញា ២០១១



ពាក្យថា «ចង់ចេះឲ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កាឲ្យយកភ្លើងដុតគល់» នេះ ពុំមែនមានន័យថា សម្លាប់ជីវិតអាចារ្យជាអ្នកបង្រៀន និងយកភ្លើងទៅដុតគល់ដើមឈើឲ្យវាងាប់នោះឡើយ ។ សម្លាប់អាចារ្យ គឺសម្លាប់ទឹកចិត្តអាចារ្យឬគ្រូបង្រៀន ឲ្យលោកពេញចិត្តផ្តល់ចំណេះដឹងរបស់លោកមកឲ្យខ្លួនជាសិស្ស ដោយមិនលាក់ទុក ។ ការដែលធ្វើឲ្យលោកពេញចិត្ត គ្មានអ្វីក្រៅពីសិស្សយកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ មករៀនឲ្យទាន់ពេលវេលា បំពេញកិច្ចការដែលគ្រូដាក់ឲ្យធ្វើជាដើម ។ ពាក្យខ្មែរមួយបទទៀតពោលថា ប្រាជ្ញាបុណ្យផងកើតដោយប្រណិប័តន៍ ។ ពាក្យថាប្រណិប័តន៍ និងពាក្យថាប្រតិបត្តិមានន័យផ្សេងគ្នា ។ ពាក្យថាប្រណិប័តន៍ហាក់ដូចជាមានន័យថា គោរពគ្រូ ប៉ុន្តែពុំមែនគោរពតបៀបលុតក្រាបហួសហេតុ ដូចសម័យអាណានិគមនិយមបារាំងមកលើប្រទេសកម្ពុជាពីមួយសតវត្សរ៍មុន ដែលពេលនោះសិស្សខ្មែរខ្លាចគ្រូបង្រៀនយ៉ាងខ្លាំងក្លាបំផុត ដោយសារគ្រូសម័យនោះប្រើអំពើហឹង្សា វាយដំសិស្សដោយកំហុសបន្តិចបន្តួច ។ ប៉ុន្តែសម័យក្រោយមក ដោយមានការជឿនលឿនខាងគរុកោសល្យ គ្រូបង្រៀនមិនវាយដំសិស្សឡើយ បើមានការវាយដំសិស្ស គ្រូនោះនឹងត្រូវមានទោសដោយការរំលោភសិទ្ធិកុមារ រំលោភច្បាប់ជាតិ និងច្បាប់អង្គការសហប្រជាជាតិ ។

សម័យដើម សិស្សខ្លះចូលទៅគួរសមបំរើគ្រូ ដើម្បីឲ្យគ្រូអាណិតជួយណែនាំពន្យល់ខ្លួនឲ្យបានចេះដឹង ដោយមិនលាក់ចំណេះវិជ្ជា ។ ដោយឃើញកិរិយាសមរម្យដូច្នេះ គ្រូក៏កើតចិត្តអាណិតសិស្សកាន់តែខ្លាំងឡើងថែមទៀត ក៏ខំជួយបង្ហាត់បង្រៀនអស់ពីសមត្ថភាពរបស់ខ្លួន ដើម្បីជួយឲ្យសិស្សឆាប់ចេះដឹង ។ ព្រះពុទ្ធសាសនាក៏មាននិយាយថា ពេលឃើញគ្រូ សិស្សក្រោកទទួល ហើយត្រូវស្តាប់ពាក្យប្រៀនប្រដៅរបស់លោកដោយគោរព ។ ការស្តាប់ពាក្យរបស់គ្រូនេះ ចំពោះតែគ្រូដែលណែនាំនិងអប់រំទៅរកផ្លូវល្អផ្លូវត្រូវ ។ បើគ្រូអប់រំផ្លូវខុសមិនត្រូវយកពាក្យនោះមកធ្វើតាមឡើយ ។ ពាក្យខ្មែរមួយបទទៀតពោលថា «ពុតគ្រូកុំត្រាប់ ច្បាប់គ្រូឲ្យយក» ។ ពាក្យនេះមានន័យថា គ្រូប្រព្រឹត្តខុសកុំធ្វើតាម តែពាក្យរបស់លោកគួរយកចិត្តទុកដាក់ស្តាប់ ។ ប៉ុន្តែសម័យទំនើបនេះ គ្រូបង្រៀនត្រូវមានចរិយាល្អផង មានចំណេះជាគ្រូបង្រៀនផង ទើបធ្វើជាគ្រូបង្រៀនបាន ព្រោះគ្រូជាគំរូដល់សិស្ស ។ ចំណែកពាក្យថា «ប្រតិបត្តិ» បានសេចក្តីថា សេចក្តីព្យាយាម ការអនុវត្តន៍ ឬបំពេញកិច្ចការអ្វីមួយ ។ ព្រះពុទ្ធសាសនាក៏ប្រើពាក្យថា «ប្រតិបត្តិ» ដូចប្រតិបត្តិតាមសីលសមាធិបញ្ញា ដើម្បីសំរេចព្រះនិព្វានជាដើម ។ ផ្លូវលោកក៏មានប្រើពាក្យអនុវត្តនិងប្រតិបត្តិនេះដែរ ដូចពាក្យថា ត្រូវអនុវត្តតាមឬប្រតិបត្តិតាមច្បាប់ជាតិច្បាប់អន្តរជាតិជាដើម ។ ឯពាក្យថា «ប្រណិប័តន៍» ដែលមានន័យថាការគោរពគ្នានេះ ពុំមែនជាសកម្មភាពហួសសម័យទេ តែជាការធម្មតារបស់មនុស្សដែលមានសុជីវធម៌ និងសីលធម៌វិញទេ ។ ចំពោះគ្រូបង្រៀនវិញ ក៏ត្រូវបង្ហាត់បង្រៀនសិស្សប្រកបដោយមេត្តាចិត្ត ដើម្បីឲ្យសិស្សចេះដឹង ទោះបីមានកង្វះខាតខាងការគោរពពីសិស្សក៏ដោយ ព្រោះនេះជាមុខនាទីរបស់ខ្លួនដែលរដ្ឋផ្តល់ឲ្យ ដោយទទួលបៀវត្សរ៍ពីប្រជាពលរដ្ឋ ត្រូវបំរើប្រជាពលរដ្ឋវិញ ។ តាមព្រះពុទ្ធសាសនា ការគោរពគ្នាទៅវិញទៅមកតាមមុខងារនាទីរបស់ខ្លួន ជាធម៌របស់មនុស្សដែលផ្សេងពីសត្វតិរច្ឆាន ។ ដូចពោលមកហើយ ពាក្យថាចង់ចេះឲ្យសម្លាប់អាចារ្យ គឺសម្លាប់ទឹកចិត្តរបស់អាចារ្យឬគ្រូបង្រៀនដោយសិស្សត្រូវគោរពច្បាប់សាលានិងគោរពគ្រូ ដើម្បីឲ្យគ្រូពេញចិត្តផ្តល់ចំណេះដឹងឲ្យខ្លួនដោយមិនលាក់ទុក ពុំមែនសម្លាប់រូបរាងកាយ ឬសម្លាប់ជីវិតឡើយ ។

ពាក្យថា «ចង់បានផ្លែផ្កាឲ្យយកភ្លើងដុតគល់» គឺដុតឬលះបង់សេចក្តីខ្ជិលច្រអូស ទើបផ្លែផ្កាឬផលសំរេចគ្រប់យ៉ាងកើតឡើងបាន ។ សេចក្តីថា ផ្លូវលោកក៏ដូចជាផ្លូវធម៌ ការសំរេចផលគ្រប់យ៉ាង កើតពីសេចក្តីព្យាយាមធ្វើមិនខ្ជិលច្រអូស ។ ផ្លូវធម៌ ពុទ្ធបរិស័ទចង់សំរេចព្រះនិព្វានជាការរំលត់ទុក្ខ ត្រូវប្រតិបត្តិតាមទានសីលភាវនា ឬសីលសមាធិបញ្ញាឲ្យបានម៉ត់ចត់បំផុត ។ ផ្លូវលោកដើម្បីឲ្យប្រទេសចំរើនលូតលាស់ខាងសង្គមកិច្ចនិងវប្បធម៌ អ្នកដឹកនាំជាតិនិងប្រជាពលរដ្ឋ គប្បីបំពេញកិច្ចការឲ្យបានខ្លាំងក្លាតាមមុខងារនិងនាទីរបស់ខ្លួន ។ ពាក្យខ្មែរមួយបទពោលថា ព្រេងនឹងប្រឹងជាគូគ្នា ។ បានសេចក្តីថា បើទោះបីមានព្រេងវាសនាមានសំណាងបានកសាងពីមុនមកហើយក៏ដោយ ក៏ត្រូវតែខំប្រឹងប្រែងព្យាយាមធ្វើក្នុងបច្ចុប្បន្ននេះទៀត ទើបសំរេចផលបាន ។ ដូចបានពោលមកហើយ យកភ្លើងដុតគល់នេះ គឺកំចាត់មេខ្ជិលហើយខំប្រឹងប្រែងបំពេញការងារទើបផលគ្រប់យ៉ាងសំរេចបាន ពុំមែនដុតគល់ឈើឲ្យដើមរលំនោះឡើយ ។៚

*　　　*

*